

NAGAWORLD®
金界

**សម្រាប់ចុះផ្សាយបន្ទាន់ ៖**
**១៥ វិច្ឆិកា ២០១៩**

# ណាហ្គាវើលដ៍បេះដូងសប្បុរស ចូលរួមអភិវឌ្ឍយុវជន និងកីឡា

*រាជធានីភ្នំពេញ៖* នាព្រឹកថ្ងៃសុក្រ ទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ណាហ្គាវើលដ៍បេះដូងសប្បុរសដែលជាផ្នែកទំនួលខុសត្រូវសង្គមរបស់ក្រុមហ៊ុនណាហ្គាវើលដ៍ ក្រោមកិច្ចសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក.) បានឧបត្ថម្ភទឹកប្រាក់ចំនួន ២ លានដុល្លារសហរដ្ឋអាមេរិក ដើម្បីចូលរួមលើកកម្ពស់ "ការអភិវឌ្ឍយុវជន និងកីឡាក្នុងខេត្តកំពង់ស្ពឺ"។ ឯកឧត្តម ហ៊ុន ម៉ានី សមាជិករដ្ឋសភាតំណាងរាស្ត្រមណ្ឌលកំពង់ស្ពឺ និងជាប្រធាន ស.ស.យ.ក. បានទទួលមូលប្បទានបត្រ ពីនាយកគ្រប់គ្រងក្រុមហ៊ុនណាហ្គាវើលដ៍លោក Pern Chen នៅក្នុងពិធីដែលបានធ្វើឡើងនៅផ្សារទំនើបក្រោមដីណាហ្គាស៊ីធីវ៉កដែលមានការចូលរួមពីសំណាក់សមាជិក-សមាជិកាស.ស.យ.ក. ថ្នាក់ដឹកនាំរដ្ឋបាលខេត្តកំពង់ស្ពឺ និងភ្ញៀវកិត្តិយសជាច្រើនរូបទៀត។

គោលបំណងនៃកម្មវិធីអភិវឌ្ឍយុវជននេះ គឺដើម្បីលើកកម្ពស់ទេពកោសល្យ ជំរុញការអភិវឌ្ឍយុវជន និងផ្តល់ឱកាសបន្ថែមដល់យុវជនកម្ពុជាដើម្បីឈានទៅសម្រេចគោលដៅអនាគត និងក្តីបំណងរបស់ខ្លួនក្នុងវិស័យកីឡា និងវិស័យផ្សេងៗទៀត។ ណាហ្គាវើលដ៍បេះដូងសប្បុរស ជឿជាក់ថា ការឧបត្ថម្ភនេះនឹងបន្តផ្តល់ប្រយោជន៍ដល់យុវជនកម្ពុជាដូចដែលក្រុមហ៊ុនណាហ្គាវើលដ៍បានអនុវត្តក្នុងខេត្តកំពង់ស្ពឺកន្លងមកក្រោមការគាំទ្ររបស់ឯកឧត្តម ហ៊ុន ម៉ានី ។ គម្រោងទាំងនេះ រួមមាន កម្មវិធីអភិវឌ្ឍកីឡាបាល់ទាត់ក្នុងខេត្តកំពង់ស្ពឺរយៈពេល ២ឆ្នាំ ដែលផ្តល់ការបណ្តុះបណ្តាលជំនាញ បង្ហាត់កីឡាបាល់ទាត់អាជីពដល់គ្រូអនុវិទ្យាល័យ និងវិទ្យាល័យ បូករួមនឹងការឧបត្ថម្ភសម្ភារៈកីឡា និងហេដ្ឋារចនាសម្ព័ន្ធកីឡាជាបន្តបន្ទាប់។

នាយកគ្រប់គ្រងក្រុមហ៊ុនណាហ្គាវើលដ៍ លោក Pern Chen បានមានប្រសាសន៍ថា "៧០% នៃប្រជាជនកម្ពុជាសរុប មានអាយុក្រោម ៣៥ឆ្នាំ។ យើងជឿជាក់ថា ការវិនិយោគទៅលើយុវជន គឺជាការវិនិយោគទៅលើអនាគតរបស់ព្រះរាជាណាចក្រកម្ពុជា។ ការលើកស្ទួយយុវជន គឺការបង្កើតការផ្លាស់ប្តូរកាន់តែប្រសើរនៅក្នុងសហគមន៍។ យើងរួមគ្នាផ្តល់ឱកាសប្រសើរជាងមុនដើម្បីឲ្យពួកគេបង្កើនគុណភាពនៃជីវិតរបស់ពួកគេផ្ទាល់ និងគ្រួសាររបស់ពួកគេ។ យើងសង្ឃឹមថា ការឧបត្ថម្ភសម្រាប់កម្មវិធីទាំងនេះ នឹងជួយបង្កើនសក្តានុពលរបស់យុវជនក្នុងខេត្តកំពង់ស្ពឺសម្រាប់សង្គមជាតិហើយដែលការនេះនឹងផ្តល់ត្រឡប់មកវិញដល់គ្រួសារ សហគមន៍ និងប្រទេសជាតិទាំងមូល"។

គួរបញ្ជាក់ផងដែរថា ក្នុងបុព្វហេតុលើកស្ទួយយុវជនឲ្យក្លាយជាសសរទ្រូងដ៏រឹងមាំរបស់សង្គម និងប្រទេសជាតិ ស.ស.យ.ក. បាន និងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការកៀរគរកិច្ចសហការជាមួយនឹងដៃគូនានាដើម្បីបង្កើតជាវេទិកាឲ្យយុវជនបានអភិវឌ្ឍសមត្ថភាពរបស់ខ្លួនជាបន្តបន្ទាប់ ដែលក្នុងនោះរួមមានទាំងការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត កិច្ចហាត់ការ ក៏ដូចជាការផ្តល់ឱកាសការងារដល់យុវជនទូទាំងប្រទេស។ ជាក់ស្តែង ក្រោមគម្រោងកិច្ចសហការជាមួយក្រុមហ៊ុនណាហ្គាវើលដ៍នេះ យុវជននឹងមានឱកាសកាន់តែប្រសើរ និងច្រើនជាងមុនក្នុងការ



អភិវឌ្ឍសមត្ថភាពខ្លួនឈានទៅចាប់យកអាជីពក្នុងវិស័យកីឡា និងវិស័យផ្សេងៗជាច្រើនទៀត។ ភាពជោគជ័យដែលកើតចេញពីកិច្ចសហការនេះ នឹងនាំទៅដល់ការពង្រីកវិសាលភាពនៃកិច្ចសហការ និងបាននូវការរីកចម្រើនសម្រាប់ទាំងអស់គ្នា។

ផ្សារភ្ជាប់ជាមួយនឹងកម្មវិធីនេះផងដែរ ណាហ្គាវើលដ៍បេះដូងសប្បុរសក៏បានលើកទឹកចិត្តឲ្យយុវជនកម្ពុជាចុះឈ្មោះ និងដាក់ពាក្យដើម្បីក្លាយជាបុគ្គលិកកម្មសិក្សានៃ "កម្មវិធីជ្រើសរើសបុគ្គលិកកម្មសិក្សាថ្មី" ដើម្បីឲ្យយុវជនរបស់យើងស្វែងយល់ពីឱកាសការងារ និងអភិវឌ្ឍជំនាញនៅក្នុងវិស័យបដិសណ្ឋារកិច្ចនៅណាហ្គាវើលដ៍។ គំនិតផ្តួចផ្តើមនៃការងារទំនួលខុសត្រូវសង្គមរបស់ណាហ្គាវើលដ៍បេះដូងសប្បុរស មានគោលបំណងលើកទឹកចិត្តឲ្យយុវជនអភិវឌ្ឍសមត្ថភាព និងទទួលបានបទពិសោធន៍ការងារដ៏មានតម្លៃនៅក្នុងមុខតំណែងជាច្រើន។ នៅពេលជាប់ជាស្ថាពរ បុគ្គលិកកម្មសិក្សានឹងទទួលបាននូវប្រាក់ឧបត្ថម្ភរហូតដល់ ៣០០ ដុល្លារក្នុងមួយខែ ការញ៉ាំម្ហូបអាហារ និងភេសជ្ជៈឥតកំណត់ ឱកាសបណ្តុះបណ្តាលបន្ថែមពេញមួយឆ្នាំ កន្លែងស្នាក់នៅតាមការស្នើសុំ និងអត្ថប្រយោជន៍ជាច្រើនទៀត។ សាធារណជនទូទៅ យុវជន សិស្សវិទ្យាល័យ និស្សិតសាកលវិទ្យាល័យ និងអ្នកដែលកំពុងស្វែងរកការងារទាំងអស់អាចដើរចូលសម្ភាសន៍ដោយសេរីរៀងរាល់ថ្ងៃនៅមជ្ឈមណ្ឌលបណ្តុះបណ្តាល Naga Academy (អគារលេខ ១៤ ផ្លូវលេខ ២៥២ រាជធានីភ្នំពេញ) ពីម៉ោង ១១ព្រឹកដល់ ៩យប់ ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ឬពីម៉ោង ៩ព្រឹកដល់ ៥ល្ងាច នៅថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ។

**អំពីផ្នែកការងារទំនួលខុសត្រូវសង្គមណាហ្គាវើលដ៍បេះដូងសប្បុរស**

ចាប់តាំងពីបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ណាហ្គាវើលដ៍ បាន និងកំពុងធ្វើសកម្មភាពសង្គមប្រកបដោយទឹកចិត្តសប្បុរស និងចូលរួមអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៃប្រទេសកម្ពុជាប្រកបដោយភាពវិជ្ជមាន។ ក្នុងខែមីនា ឆ្នាំ ២០១៤ ក្រុមការងារសង្គមណាហ្គាវើលដ៍បេះដូងសប្បុរស ត្រូវបានបង្កើតឡើងដោយបុគ្គលិកណាហ្គាវើលដ៍ដែលមានការគាំទ្រយ៉ាងពេញទំហឹងពីក្រុមហ៊ុនណាហ្គាវើលដ៍ដើម្បីលើកកម្ពស់ការធ្វើការស្ម័គ្រចិត្តសម្រាប់សង្គមកម្ពុជាទាំងមូល ដោយផ្តោតទៅលើសសរស្តម្ភ ៤ គឺការលើកកម្ពស់វិស័យអប់រំ ការផ្សារភ្ជាប់ជាមួយសហគមន៍ ការអភិវឌ្ឍវិស័យកីឡា និងការគាំពារបរិស្ថាន។ មកដល់បច្ចុប្បន្ន មានប្រជាជនកម្ពុជាជាង ២០៤.០០០ នាក់បានទទួលផលប្រយោជន៍ពីកម្មវិធីទាំងនេះ។

សម្រាប់សំណួរទាក់ទងនឹងការផ្សព្វផ្សាយ ឬរូបភាព សូមទាក់ទងមកកាន់៖


| | |
|---|---|
| Ms. Melanie Loong<br>Senior Marketing Communications Manager<br>Tel: (+855) 10 737 684<br>Email: melanieloong@nagaworld.com | កញ្ញា ភោគ សូលីនដា<br>Brand Executive, Marketing Communications<br>Tel: (+855) 15 61 88 86<br>Email: phouksolinda@nagaworld.com |